**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ**

*អត្ថបទស្រាវជ្រាវ ស្តីពី*

# បម្រែបម្រួលនៃការតម្កល់រក្សាអដ្ឋិធាតុនៅក្នុងសង្គមខ្មែរ
## ករណីសិក្សា ៖ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ



*ដោយ ប្រែង ពិសិដ្ឋ*

*លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា*

*ខែកក្កដា ឆ្នាំ២០១៩*

## សេចក្តីផ្តើម

អត្ថបទនេះពុំមែនជាការសិក្សាស្រាវជ្រាវស៊ីជម្រៅនោះទេ តែវាលេចឡើងតាមរយៈការអង្កេតជាជំហានដំបូងទៅលើរបៀបនៃការតម្កល់ក្បោអដ្ឋិធាតុ ដែលកំពុងមានការប្រព្រឹត្តទៅនៅភូមិទាំង១១ នៃឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ នោះគឺការតម្កល់ក្បោអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតា។ ចលនានេះបានកើតឡើងប្រមាណជិតមួយទសវត្សមកហើយ តែវាមានការផុសផុលខ្លាំងនៅប្រមាណជាប្រាំមួយឆ្នាំនេះ។ ភូមិខ្លះទើបបានចាប់ផ្តើមចលនានេះប្រមាណតែពីរឆ្នាំ ហើយមានករណីតម្កល់ក្បោអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតានេះតែបីឬបួនគ្រួសារប៉ុណ្ណោះ ជាអាទិ៍មានភូមិព្រៃដក់ពរ ជាដើម [1] ។

អត្ថបទនេះនឹងព្យាយាមស្វែងយល់លើចំណុចមួយចំនួនដូចខាងក្រោម៖

- មូលហេតុនៃការប្រតិបត្តិតម្កល់ក្បោអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតា
- ការបញ្ញត្តិព្រះភូមិឬរានទេវតាដែលប្រើតម្កល់ក្បោអដ្ឋិធាតុ
- ស្ថានភាពនៃចលនាតម្កល់ក្បោអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតានៅពេលអនាគត។

## ទិដ្ឋភាពប្រវត្តិសាស្ត្រនៃការទុកដាក់សពក្នុងសង្គមខ្មែរ

ខ្មែរមានទម្លាប់គោរពអ្នកបាត់បង់ជីវិត ដែលជាសាច់ញាតិរបស់ខ្លួន ដោយបានបញ្ចុះជាមួយសពនូវសំណែនផ្សេងៗ មានជាអាទិ៍ ម្ហូបអាហារ សម្ភារៈប្រើប្រាស់ និង គ្រឿងអលង្ការ។ ខ្មែរបញ្ចុះសពនៅក្រោមផ្ទាំងថ្មធំៗ ក្នុងក្តារមឈូស ឬ ក្នុងក្រឡធ្វើអំពីដីដុត។ បុព្វបុរសខ្មែរបញ្ចុះសពឱ្យអង្គុយចោងហោងក្នុងក្រឡ មានលក្ខណៈដូចជាទារកនៅក្នុងផ្ទៃម្តាយមុនពេលកើត ដោយជឿថា មនុស្សស្លាប់ តែព្រលឹងមិនស្លាប់ទេ ហើយព្រលឹងនោះនឹងចាប់ជាតិជាថ្មីទៀត។

នៅសម័យហ្វូណន ទំនៀមទម្លាប់ទុកដាក់សពមានច្រើនរបៀប ដូចជា ការបោះសពទៅក្នុងទឹកទន្លេ ការបូជាដោយភ្លើង ការបញ្ចុះសព និង ការយកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី។ ក្នុងករណីបូជាដោយភ្លើង គេតែងប្រមូលអដ្ឋិធាតុដែលនៅសល់យកដាក់ក្នុងកោដ្ឋមួយបិទជិត ហើយបោះទៅក្នុងទន្លេ។ ចំពោះព្រះមហាក្សត្រ កោដ្ឋគឺធ្វើអំពីមាស បើជានាម៉ឺន គេប្រើកោដ្ឋប្រាក់ រីឯប្រជាជនសាមញ្ញប្រើកោដ្ឋធ្វើពីដី។ [2]

នៅសម័យចេនឡា គេឃើញមានការបូជាសពនៅក្នុងប៉ាឆាដែលសង់ដោយឈើក្រអូបច្រើនយ៉ាង បន្ទាប់មកគេរើសអដ្ឋិធាតុដាក់ក្នុងកោដ្ឋដែលធ្វើអំពីមាសឬប្រាក់ ឯចំពោះអ្នកក្រ គេប្រើកោដ្ឋធ្វើពីដីដុតមានលាបពណ៌។ គេពុំដាក់មនុស្សស្លាប់ក្នុងក្តារមឈូសទេ តែគេយកកន្ទេលក្រាលពីក្រោមយកកំណាត់សំពត់ក្រាលពីលើហើយគេយកទៅក្នុងព្រៃ។ លុះសែងដល់ទីស្ងាត់ក្នុងព្រៃជ្រៅ គេដាក់សពនោះចោល ហើយត្រឡប់មកវិញដើម្បីទុកឱ្យសត្វមកស៊ី។ គេមានជំនឿថា បើមានសត្វខ្លែងឬតិរច្ឆានអ្វីមកស៊ីសពនោះអស់ភ្លាម សពនោះមានភ័ព្វបានសុខសប្បាយល្អណាស់។ ប៉ុន្តែ បើគ្មានសត្វស៊ីសោះឬ

[1] ណុប សារិន អាយុ ៣៩ឆ្នាំ ប្រធានភូមិព្រៃដក់ពរ ( សម្ភាសន៍ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៦)។

[2] ត្រឹង ងា ៖ *អរិយធម៌ខ្មែរ* ថ្នាក់បញ្ចប់ បោះពុម្ពលើកទី៣ ១៩៧៤ ទំព័រ ២០០ ។

មានស៊ីដែរ តែស៊ីមិនអស់វិញ គេយល់ថា សពនេះមានពៀរ មានទោស [3] ។ សម្រាប់ព្រះមហាក្សត្រ មានការសង់ប្រសាទសម្រាប់បញ្ចុះសព តែមិនដឹងថាបញ្ចុះសពទាំងមូលឬបញ្ចុះតែឆ្អឹងនោះទេ។

នៅដំណាក់កាលក្រោយមកទៀត ខ្មែរចាប់ផ្តើមជ្រើសរើសវិធីតែពីរប៉ុណ្ណោះក្នុងការទុកដាក់សពគឺ បូជា និង បញ្ចុះ។ ជាទូទៅ តាំងពីដើមមក គេមានការជូនដំណើរអ្នកស្លាប់ដោយមានប្រើភ្លេងទង់ព្រលឹង លាជពីមុខបាចតាមផ្លូវនាំមុខសពផងដែរ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមានពិធីបុណ្យជូនដំណើរសេពតាមទំនៀមទម្លាប់ប្រពៃណីនោះទេ ហើយមានមនុស្សជាច្រើនដែលមិនបានដឹងពីការស្លាប់និងកន្លែងកប់សពសាច់ញាតិរបស់ខ្លួនដោយគេតម្រូវឱ្យធ្វើការនៅកន្លែងដទៃពីគ្នា ហើយជាទូទៅគេមិនតម្រូវឱ្យនៅមើលថែរសាច់ញាតិជាអ្នកជំងឺឡើយ។ នៅជំនាន់នោះ សពទាំងឡាយសុទ្ធសឹងត្រូវបញ្ចុះ ហើយផ្នូរជាច្រើនមានផ្ទុកសាកសពច្រើននិងមិនមានពូនដីសម្រាប់ជាទីគោរពសក្ការៈឡើយ។ វាជាស្ថានភាពដែលមិនឱ្យតម្លៃមនុស្ស ធ្វើឱ្យមនុស្សមិនសូវយកចិត្តទុកដាក់ដល់ជីវិតមនុស្ស ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សីលធម៌និងទំនួលខុសត្រូវក្នុងនាមជាមនុស្សជាតិ។ វាជាការប្រែប្រួលដ៏ធំមួយក្នុងការវិវត្តនៃរបៀបទុកដាក់សពក្នុងសង្គមខ្មែរ។

ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ប្រពៃណីទំនៀមទម្លាប់ត្រូវបានរស់ឡើងវិញ។ សពទាំងឡាយត្រូវបានបញ្ចុះឬបូជាដោយមានរៀបចំតាមកិច្ចពិធីត្រឹមត្រូវ។ បច្ចុប្បន្ន ខ្មែរនិយមទុកដាក់សពតាមពីររបៀប គឺ បញ្ចុះ និង បូជា តែប្រជាជនហាក់និយមការបូជាសពច្រើនជាងការបញ្ចុះ។ គេក៏អាចយកសពទៅបញ្ចុះមួយរយៈមុននឹងគេធ្វើបុណ្យលើកសពរើសធាតុដាក់ក្នុងកោដ្ឋ ហើយយកទៅរក្សាទុកនៅផ្ទះឬនៅក្នុងចេតិយដែរ។ [4]

## ការតម្កល់រក្សាអដ្ឋិធាតុនៅឃុំត្រពាំងធំខាងជើង

### ឃុំត្រពាំងធំខាងជើង

ឃុំត្រពាំងធំខាងជើងស្ថិតនៅក្នុងដែនរដ្ឋបាលនៃស្រុកត្រាំកក់ ខេត្តតាកែវ។ ឃុំនេះមានប្រវត្តិនៃការវិវត្តជាដំណាក់កាលបែបប្រវត្តិសាស្ត្រ ដោយមុនរបបកម្ពុជាប្រជាធិបតេយ្យមិនមានឃុំត្រពាំងធំខាងជើងនិងត្រពាំងធំខាងត្បូងឡើយ គឺមានតែឃុំត្រពាំងធំប៉ុណ្ណោះ [5] ។ ឃុំត្រពាំងធំខាងជើងមានភូមិចំណុះចំនួន ១១ ៖ ភូមិអង្គត្រាវ ភូមិពាក់បង្អោង ភូមិត្រពាំងស្វាយ ភូមិព្រៃដក់ពរ ភូមិព្រៃខ្វាវ ភូមិព្រៃក្តួច ភូមិពោធិដុះ ភូមិតាសួន ភូមិព្រៃស្បាត ភូមិព្រៃតាឡី និង ភូមិសំរ៉ោង។

បច្ចុប្បន្ន ជីវភាពប្រជាជននៅក្នុងឃុំត្រពាំងធំខាងជើងពឹងផ្អែកជាចម្បងលើរបរធ្វើស្រែនិងការងារនៅតាមរោងចក្រ។ ដោយមួយភាគធំនៃយុវជន យុវនារី ដែលជាសមាជិកពេញកម្លាំងនៅតាមគ្រួសារនីមួយៗ បានប្រកបការងារនៅតាមរោងចក្រ នោះការងារស្រែចម្ការបានធ្លាក់ទៅលើមនុស្សវ័យ

---

3 លី ធាមតេង៖ *កំណត់ហេតុរបស់ជីវតាក្វាន់អំពីប្រពៃណីអ្នកស្រុកចេនឡា* បោះពុម្ពលើកទី៣ ភ្នំពេញ ១៩៧៣ ទំព័រ ៤៥។

4 ត្រឹង ងា ៖ *អរិយធម៌ខ្មែរ* ថ្នាក់បញ្ចប់ បោះពុម្ពលើកទី៣ ១៩៧៤ ទំព័រ ២០១ ។

5 សៀក ឈួន (ហៅអាចារ្យណុប) អាយុ៧៩ឆ្នាំ ជាអាចារ្យវត្តសិរីជំណាក់ រស់នៅភូមិអង្គត្រាវ (សម្ភាសន៍ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦)។

ច្រើននៅក្នុងគ្រួសារ។ ដោយខ្វះកម្លាំងពលកម្មធ្វើស្រែ ប្រជាជនភាគច្រើនបានផ្លាស់ប្តូរវិធីយាបថក្នុងការធ្វើស្រែ ដោយពួកគាត់ងាកមកធ្វើស្រែជាពង្រោះនិងប្រើគ្រឿងចក្រ ជំនួសឱ្យការធ្វើស្រែជារបៀបប្រពៃណីដោយការដកស្ទូងនិងពឹងផ្អែកលើកម្លាំងសត្វនិងកម្លាំងមនុស្សជាធំ។ ក្រៅពីនេះ មានប្រជាជនខ្លះបានប្រកបអាជីវកម្មផ្សេងៗ ដូចជា ចិញ្ចឹមមាន់ ចិញ្ចឹមចង្រិត ចិញ្ចឹមជ្រូក ជាដើម ។

ដោយឡែកចំពោះជំនឿ ការគោរពបូជា និង កិច្ចពិធីផ្សេងៗក្នុងឃុំនេះ ក៏នៅមានការប្រតិបត្តិច្រើនដែរ ដូចជា ជំនឿលើអ្នកតា ការធ្វើពិធីសុំទឹកភ្លៀង បុណ្យដារលាន ព្រះសង្ឃបិណ្ឌស្រូវ សង្គហធម៌ និង ការតម្កល់រក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតាតាមផ្ទះសម្រាប់គោរពប្រណិប័តន៍។

ផ្នូរបញ្ចុះសព

ដើមឡើយ ប្រជាជននៅក្នុងឃុំត្រពាំងធំខាងជើងនិយមជ្រើសយកការបញ្ចុះសពច្រើនជាងការបូជា។ នៅក្នុងភូមិខ្លះនៃឃុំនេះមានព្រៃសម្រាប់បញ្ចុះសពរួមគ្នារបស់ប្រជាជន ដែលគេហៅថា ព្រៃជាតុ។ ដូច្នេះ ព្រៃជាតុជាទីប្រជុំនៃផ្នូរបញ្ចុះសពរបស់អ្នកភូមិ។ ប្រជាជនកម្របញ្ចុះសពនៅក្នុងវត្តអារាមណាស់។ ទោះបីជាបច្ចុប្បន្នប្រជាជនពុំបានបន្តបញ្ចុះសពរួមគ្នានៅព្រៃជាតុនោះទៀតក្តី តែព្រៃជាតុនេះនៅបន្តជាទីសក្ការៈរហូតបច្ចុប្បន្ន ដោយពុំមានការកាន់កាប់ជាកម្មសិទ្ធិឯកជនឡើយ។

ផ្នូរអាចកើតមានតាមករណីមួយទៀត គឺតាមរយៈការពូនដីជាផ្នូរនៅទីបូជាសពបន្ទាប់ពីរើសអដ្ឋិធាតុសម្រាប់ដាក់រក្សាក្នុងកោដ្ឋរួច។ ជាទូទៅ ការបូជាសពនៅក្នុងឃុំនេះ ក៏ដូចនៅទូទាំងប្រទេសដែរ ទោះបីរៀបចំនៅក្នុងវត្តអារាមឬនៅតាមផ្ទះក្តី(ករណីពុំមានឈាបនដ្ឋាន) គេតែងរៀបចំឡើងនៅផ្ទាល់នឹងដី ដែលធ្វើឱ្យកម្ទេចអដ្ឋិធាតុនិងធ្យូងត្រូវស្ថិតនៅលើដីផ្ទាល់បន្ទាប់ពីបូជារួច។ ហេតុនេះបន្ទាប់ពីរើសអដ្ឋិធាតុដាក់ក្បោក្នុងកោដ្ឋរួច សមាជិកគ្រួសារបានពូនដីនៅទីបូជានោះជាផ្នូរដើម្បីជាទីសក្ការៈ (ជាពិសេសការបូជាតាមផ្ទះ) ដោយគេយល់ថា នៅទីនោះនៅមានអដ្ឋិធាតុនៃមនុស្សជាទីគោរពស្រឡាញ់របស់គេដែលរើសពុំអស់។

បច្ចុប្បន្ន ប្រជាជននៅក្នុងឃុំត្រពាំងធំខាងជើងមានទំនោរនិយមបូជាសពជាជាងការបញ្ចុះសពវិញ។ ក្រុមគ្រួសារដែលនៅនិយមបញ្ចុះសពនៅមានចំនួនតិចតួចប៉ុណ្ណោះ ដែលភាគច្រើនជាគ្រួសារមានសែស្រឡាយចិន ដែលមានប្រពៃណីបញ្ចុះសព តែមិនបូជាសព។ ទំនោរនិយមបូជាសពនេះ ធ្វើឱ្យកំណើនផ្នូរបញ្ចុះសពនៅក្នុងឃុំត្រពាំងធំមានតែបន្តិចបន្តួចប៉ុណ្ណោះ។ ហេតុនេះ ផ្នូរបញ្ចុះសពនៅក្នុងឃុំនេះភាគច្រើនជាផ្នូរចាស់ៗ ទោះបីជាមានរបងព័ទ្ធជុំវិញថ្មីក៏ដោយ។

ទោះបីជាវាពុំមែនជារឿងថ្មី តែបច្ចុប្បន្នចលនាធ្វើរបងព័ទ្ធជុំវិញផ្នូរឬការធ្វើរោងគ្របលើផ្នូរកាន់តែមានលក្ខណៈរឹងមាំ [6] និងមានសណ្ឋានប្លែកៗ ទាំងចំពោះផ្នូរចាស់ ទាំងចំពោះផ្នូរថ្មី។ មូលហេតុនៃចលនានេះគឺផ្តើមចេញពីការគោរពស្រឡាញ់សពជាអ្នកមានគុណ ជាញាតិសន្តានបងប្អូន ដែលអមដោយលទ្ធភាពខាងសេដ្ឋកិច្ចនិងសេចក្តីសង្ឃឹមតាមបែបអរូបីពីទង្វើនេះ។

ការគោរពស្រឡាញ់សពធ្វើឱ្យគ្រួសារសពមានបំណងរក្សាសពក្នុងស្ថានភាពល្អខ្ពង់ខ្ពស់ ជាទីគោរពសក្ការៈ មិនចង់ឱ្យមានសត្វពាហនៈបៀតបៀនឬជាន់ផ្នូរនេះទេ។ គេមានជំនឿថា ប្រសិនបើគេពុំ

---

[6] ពីដើម គេសាងដោយឈើ បច្ចុប្បន្នគេសាងដោយថ្មស៊ីម៉ង់។

បានរក្សាផ្នូរសពអ្នកមានគុណឬមនុស្សជាទីគោរពស្រឡាញ់បានល្អទេ នោះសពនឹងដាក់ទោសទណ្ឌឱ្យជួបនូវរឿងអកុសល្យផ្សេងៗ។ ផ្ទុយទៅវិញ គេជឿថា ប្រសិនបើគេរក្សាសពអ្នកមានគុណបានល្អ នោះគេនឹងទទួលបានមកវិញនូវសេចក្ដីសុខសប្បាយនិងលាភជ័យក្នុងគ្រួសារ។ ការណ៍នេះនាំឱ្យសមាជិកគ្រួសារកាន់តែយកចិត្តទុកដាក់ក្នុងការរក្សាផ្នូរសពឱ្យបានល្អ។

ទន្ទឹមនេះ ការរក្សាផ្នូរសពបានល្អ ដោយមានរោងធំឬរបងខ្ពស់ ក៏បង្ហាញអំពីគុណធម៌និងភាពខ្ពង់ខ្ពស់នៃគ្រួសារដែរ ទាំងក្នុងទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គម។ ការធ្វើរោងធំក៏ផ្ដល់នូវភាពងាយស្រួលក្នុងកិច្ចពិធីសែនព្រេនដល់សពដែរ ដោយងាយរៀបចំគ្រឿងសក្ការៈនិងពុំស្ថិតនៅក្រោមកម្ដៅព្រះអាទិត្យដោយផ្ទាល់។ ទោះជាយ៉ាងណា សកម្មភាពទាំងនេះគឺទាមទារនូវការគាំទ្រខាងផ្នែកសេដ្ឋកិច្ច ពោលគឺដោយសារប្រជាពលរដ្ឋមានជីវភាពល្អធូរធារទើបពួកគេអាចធ្វើបែបនេះបាន [7] ។



ផ្នូរមានរបងថ្មព័ទ្ធជុំវិញ



ផ្នូរមានរបងថ្មព័ទ្ធជុំវិញនិងមានរានទេវតានៅខាងមុខច្រកចូលក្នុងរបងនេះ

[7] ជិន សារឿន អាចារ្យវត្តមង្គលមានលក្ខណ៍ រស់នៅភូមិព្រៃជក់ពរ (សម្ភាសន៍ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦)។



ផ្នូរមានរបង មានរោង និង មានរានទេវតា

ការដាក់ឱ្យមានព្រះភូមិឬរានទេវតានៅក្បែរផ្នូរបញ្ចុះសពនេះ គឺដើម្បីងាយស្រួលគោរពបូជា និងសែនព្រេនសំណែនផ្សេងៗ ដូចជា បង្អែម ចំណីអាហារ និង ផ្លែឈើផ្សេងៗ ជាដើម ដោយគេមានបំណងដាក់សំណែនទាំងនោះនៅទីកន្លែងដែលសមគួរ។ ក្នុងន័យម្យ៉ាងទៀត សមាជិកគ្រួសារមានបំណងឧទ្ទិសដល់ព្រះភូមិដែលជាអ្នកឃុំគ្រងរក្សាទឹកដីទីនោះ សុំឱ្យជួយថែរក្សាទីកន្លែងដីដូនជីតានិងញាតិសន្តានឬភូមិស្រុកគេផងដែរ។

### ការតម្កល់រក្សាអដ្ឋិធាតុក្នុងព្រះភូមិឬរានទេវតា

ពីមុន ប្រជាជននៅឃុំត្រពាំងធំខាងជើង ក៏ដូចជាប្រជាជនកម្ពុជានៅទូទាំងប្រទេសដែរ តែងរក្សាអដ្ឋិធាតុ(ក្នុងកោដ្ឋ)នៅក្នុងចេតិយរួមគ្នានៅតាមទីវត្តអារាម នៅក្នុងចេតិយកសាងផ្ទាល់ដោយគ្រួសារ ឬ រក្សានៅក្នុងផ្ទះតែម្តង។ ប្រជាជនរក្សាអដ្ឋិធាតុនៅក្នុងចេតិយរួមនៅវត្តអារាមដោយសារគេពុំមានលទ្ធភាពខាងសេដ្ឋកិច្ចដើម្បីកសាងចេតិយដោយផ្ទាល់ខ្លួន ដោយគេមិនហ៊ានយកមករក្សាទុកក្នុងផ្ទះ ឬ ដោយគេយល់ថា នៅទីវត្តអារាមជាទីដ៏សមគួរព្រោះមានគ្នាច្រើន(មានអដ្ឋិធាតុដទៃទៀតច្រើន) និងមានសំឡេងធម៌ជារៀងរាល់ថ្ងៃ។ ខ្មែរយើងមានជំនឿថា បន្ទាប់ពីមនុស្សស្លាប់ទៅ ព្រលឹងវិញ្ញាណមិនសូន្យទេ តែគឺនៅមានអត្ថិភាពបន្តនៅឡើយ។

បច្ចុប្បន្ន ការរក្សាអដ្ឋិធាតុនៅឃុំត្រពាំងធំខាងជើងមានការប្រែប្រួល ដោយមានលេចឡើងនូវចលនាតម្កល់រក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតា។ តាមពិត ចលនារក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតាបានកើតមានប្រមាណជិតមួយទសវត្សមកហើយ តែចលនានេះកាន់តែផុលផុសខ្លាំងនៅប្រមាណជាប្រាំមួយឆ្នាំនេះ [8] ។ ការនិយមរក្សាអដ្ឋិធាតុបែបនេះមានកត្តាបីសំខាន់ គឺ សុវត្ថិភាពនៃអដ្ឋិធាតុ កត្តាសេដ្ឋកិច្ច និង ភាពងាយស្រួលក្នុងការគោរពប្រណិប័តន៍។

---

[8] អិត ស៊ីន អាយុ៥៦ឆ្នាំ អ្នកលក់រានទេវតានៅក្នុងភូមិព្រៃស្បាត (សម្ភាសន៍ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦)។

ដើមឡើយ ប្រជាជននិយមរក្សាអដ្ឋិធាតុនៅក្នុងចេតិយរួមគ្នានៅតាមទីវត្តអារាម។ នៅពេលវត្ត រៀបចំធ្វើបុណ្យឡើងសាលា ប្រជាជនយកអដ្ឋិធាតុនៃសពមនុស្សជាទីគោរពស្រឡាញ់របស់ខ្លួនមក ចូលរួមឆ្លងក្នុងពិធីបុណ្យនេះ រួចរក្សាទុកអដ្ឋិធាតុនោះនៅក្នុងចេតិយរួមគ្នាក្នុងទីវត្តអារាមនោះ។ ប៉ុន្តែ មួយរយៈកាលចុងក្រោយនេះ ការរក្សាអដ្ឋិធាតុអ្នកមានគុណឬសាច់ញាតិជាទីគោរពស្រឡាញ់នៅតាម ទីវត្តអារាមពុំមានសុវត្ថិភាពពេញពេញឡើយ ដោយពេលខ្លះត្រូវវង្វេងច្រឡំកោដ្ឋអដ្ឋិធាតុនោះ ហើយ ពេលខ្លះត្រូវបាក់បែកកោដ្ឋ ឬ ត្រូវគេលួចបាត់តែម្តង។ ការរក្សាអដ្ឋិធាតុច្រើននៅក្នុងចេតិយរួមមួយ តែងមានការច្រឡំវង្វេង ដោយពុំដឹងថាកោដ្ឋណាមួយជារបស់សាច់ញាតិខ្លួន ជាពិសេសនៅពេលបាត់ ស្លាកឈ្មោះនៃសព។ ម្យ៉ាងទៀត គឺមានអ្នកលួចយកអដ្ឋិធាតុទៅចាក់ចោលដើម្បីយកកោដ្ឋទៅលក់ ដែលករណីទាំងពីរនេះធ្វើឱ្យសមាជិកគ្រួសារយល់ថាខ្លួនមានកំហុសធ្ងន់ចំពោះសព។ អសុវត្ថិភាពនៃ ការរក្សាអដ្ឋិធាតុនេះធ្វើឱ្យប្រជាជនទទួលយកនូវជម្រើសផ្សេងដែលមានសុវត្ថិភាពប្រសើរជាងនេះ។

ដើម្បីសុវត្ថិភាពអដ្ឋិធាតុ ប្រជាជនអាចមានជម្រើសមួយចំនួនគឺ កសាងចេតិយផ្ទាល់គ្រួសារ សម្រាប់រក្សាអដ្ឋិធាតុ ឬ យកអដ្ឋិធាតុរក្សាទុកក្នុងផ្ទះតែម្តង។ ជាទូទៅ ការកសាងចេតិយផ្ទាល់គ្រួសារ គឺត្រូវចំណាយថវិកាច្រើន ដែលពិបាកចំពោះប្រជាជនមានស្ថានភាពជីវភាពមធ្យមនិងជីវភាពកម្រិត ទាបនៅក្នុងឃុំ។ ទន្ទឹមនេះ ការរក្សាអដ្ឋិធាតុក្នុងផ្ទះតែងធ្វើឱ្យសមាជិកគ្រួសារពុំមានអារម្មណ៍សុំានៅ ឡើយ ដោយគេអាចខ្លាចអដ្ឋិធាតុនោះ ដូចអ្វីដែលគេតែងសូត្រថា « *ស្លាប់ទៅតែម្នាក់ឯង កូនចៅតែង រៀបចំឱ្យប្រវែងដីបណ្តោយតែបួនហត្ថសម្រាប់កប់ ប្រសិនជាដុត ឆ្អឹងនោះវិញមួយកញ្ចប់ គេខ្លាចខ្មោច ស្អប់មិនហ៊ានខ្ចប់ទុកលើផ្ទះ* »[9] ។ ដូច្នេះ ជម្រើសទាំងពីរនេះគឺនៅពុំទាន់សមស្រប នៅឡើយសម្រាប់ ប្រជាជនទូទៅនៅក្នុងឃុំត្រពាំងធំខាងជើង។

ប្រជាជនក្នុងឃុំបានទទួលយកនូវរបៀបនៃការប្រណិបត័ន៍ថ្មីមួយ នោះគឺការរក្សាអដ្ឋិធាតុសព នៅក្នុងព្រះភូមិឬរានទេវតា ព្រោះការចំណាយតិច ដែលសាកសមសម្រាប់លទ្ធភាពប្រជាជនទូទៅក្នុង ឃុំ។ គេអាចចំណាយត្រឹមតែប្រមាណម្ភៃម៉ឺនរៀលប៉ុណ្ណោះសម្រាប់ជម្រើសនេះ ដែលប្រជាជនមាន ជីវភាពកម្រិតទាបក៏អាចដោះស្រាយទិញព្រះភូមិឬរានទេវតាតូចល្មមដើម្បីរក្សាអដ្ឋិធាតុសពមនុស្សជា ទីគោរពស្រឡាញ់របស់ខ្លួនបានដែរ។ ម៉្យាងទៀត ជម្រើសនេះមិនទាមទារឱ្យប្រើទីធ្លាដីភូមិធំទេ ខណៈ ដែលការសាងសង់ចេតិយអាចប្រើទីធ្លាដីលើសនេះច្រើន។

កត្តាសំខាន់មួយទៀតដែលប្រជាជនទទួលយកជម្រើសនេះ គឺដោយសារការរក្សាអដ្ឋិធាតុក្នុង ព្រះភូមិឬរានទេវតានៅក្បែរផ្ទះ នាំមកនូវភាពងាយស្រួលក្នុងការគោរពប្រណិប័តន៍ផ្សេងៗ។ ប្រជាជន អាចគោរពប្រណិប័តន៍ អុជធូបថ្វាយបង្គំ សែនព្រេនសំណែនផ្សេងៗបានដោយងាយទៅតាមរដូវកាល នៃពិធីសាសនានិងទំនៀមទម្លាប់ផ្សេងៗ ជាអាទិ៍ នៅថ្ងៃឧបោសថសីល និង ពេលវេលាមង្គលជាដើម។

ជារួម ការចំណាយថវិកាតិច អដ្ឋិធាតុអ្នកមានគុណមានសុវត្ថិភាព នៅក្បែរផ្ទះ ងាយគោរព បូជា ជាកត្តាសំខាន់ៗដែលនាំឱ្យប្រជាពលរដ្ឋជ្រើសរើសការរក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតា។ ការណ៍នេះបានធ្វើឱ្យគ្រួសារដែលរក្សាអដ្ឋិធាតុក្នុងផ្ទះងាកមករក្សាក្នុងព្រះភូមិឬរានទេវតាវិញដែរ។

---

[9] ដួង ជឿន អាយុ៧៨ឆ្នាំ អាចារ្យវត្តអង្គស្អាត នៅភូមិព្រៃស្បាត (សម្ភាសន៍ថ្ងៃ២៧ ខែតុលា ឆ្នាំ២០១៦)។

ព្រះភូមិ ឬ រានទេវតា ឬ ចេតិយ ?

សៀវភៅ *ប្រជុំរឿងព្រេងខ្មែរ* ភាគទី៩ បានសរសេរថា ខ្មែរមានទំនៀមសែនព្រះភូមិនេះតាំងពីបុព្វសម័យមក តែកាលនោះគឺសែនព្រេនទាក់ទងនឹងដំណឹងសួរទឹកភ្លៀងដើម្បីធ្វើស្រែ។ កាលណោះនៅកន្លែងខ្លះនៃកម្ពុជរដ្ឋ បើកាលណាមានភ្លៀងធ្លាក់ជ្រាយដីល្មមចាប់ប្រកបរបរធ្វើស្រែហើយ គេច្រើនឃើញប្រជាជនធ្វើច្រម[10] ដាក់បាយសម្ល នំចំណី យកទៅដោតសែនក្នុងស្រែរបស់ខ្លួនដើម្បីឱ្យស្រូវបានផលច្រើន ហើយគេច្រើនហៅពីធីនេះថា សែនព្រះភូមិ ។ លុះក្រោយមក អ្នកស្រុកភ្លេចរឿងដើមដោយថាសែនព្រះភូមិនេះគឺសែនទេវតាដែលរក្សាដែនដីទៅវិញ។[11]

តាមអំណះអំណាងខាងលើនេះ ជំនឿនិងការប្រតិបត្តិលើព្រះភូមិនៅក្នុងសង្គមខ្មែរបច្ចុប្បន្នបានប្រាសចាកពីខ្លឹមសារដើមរបស់វាទៅហើយ ដោយដើមឡើយ ខ្មែរប្រតិបត្តិសែនព្រេនសុំទាក់ទងនឹងដំណឹងទឹកភ្លៀងនិងទិន្នផលស្រែស្រូវ ឯបច្ចុប្បន្ន ខ្មែរប្រតិបត្តិសែនសុំទេវតាទាក់ទងនឹងការថែរក្សាភូមិដ្ឋាន ផ្ទះសម្បែង ឱ្យមានសេចក្ដីសុខសប្បាយ។ ទោះបីជាមានការប្រាសចាកពីខ្លឹមសារដើមខ្លះក្ដី តែវាជាការសែនព្រេនសុំជំនួយពីកម្លាំងក្រៅខ្លួន ដើម្បីផលល្អសម្រាប់គ្រួសារដូចគ្នា។

ទន្ទឹមនេះ ខ្មែរសម័យដើមប្រើច្រមជាវត្ថុសម្រាប់ដាក់រក្សាសំណែន ឯក្រោយមកមានការវិវត្តជាបន្តបន្ទាប់នូវវត្ថុដាក់រក្សាសំណែននេះ។ ការវិវត្តនេះអាចរាប់តាំងពីរានក្ដារឈើតូចមួយទ្រដោយជើងបង្គោលមួយដើម រហូតដល់មានរានធ្វើពីឈើឬស៊ីម៉ង់ដែលមានចម្លាក់ក្បាច់លម្អវិចិត្រផងដែរ។ ដូច្នេះពីព្រះភូមិមកជារានទេវតាគឺជាលទ្ធផលនៃការវិវត្តប្រែប្រួលនេះ។ បច្ចុប្បន្ន ក្រៅពីតួនាទីសម្រាប់សែនព្រេន ប្រជាជនក៏ប្រើព្រះភូមិឬរានទេវតានេះជាផ្នែកមួយនៃសោភ័ណភាពភូមិដ្ឋានដែរ។ ជាទូទៅ គេដាក់ព្រះភូមិឬរានទេវតានៅខាងមុខផ្ទះ ហើយបែរមុខមករកទ្វារផ្ទះ។

---

10 *ច្រម* ជាឫស្សីមួយកំណាត់ប្រវែងប្រហែលពីរម៉ែត្រដែលគេពុះចុងម្ខាងជាចម្រៀក ខ្ទាស់ញែកឱ្យមានរាងដូវផ្កាត្រកួន សម្រាប់ទ្រសំណែន។ ច្រមនេះមានគល់ខាងក្រោមស្រួចដែលគេដោតទៅនឹងដីស្រែ។

11 ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ ៖ *ប្រជុំរឿងព្រេងខ្មែរ* បោះពុម្ពលើកទី២ ២០០៣ ទំព័រ ៨៦ ។





ប្រមធ្វើពីឫស្សីសម្រាប់សែនព្រះភូមិ



ព្រះភូមិធ្វើពីឈើ



ព្រះភូមិធ្វើពីស៊ីម៉ង់បច្ចុប្បន្ន

តាមវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យ ចេតិយគឺសំដៅដល់ទីដែលគេគោរពបូជា ដែលគេជឿថាជាទីស័ក្តិសិទ្ធិ។ ទីគោរពបូជានេះអាចជាដើមឈើធំ ជាថ្មធំ ឬ ជាអ្វីដែលគេជឿថាជាទីស័ក្តិសិទ្ធិ។ ប៉ុន្តែក្រោយមករហូតដល់បច្ចុប្បន្ននេះ ខ្លឹមសារនៃបញ្ញត្តិ *ចេតិយ* មានការប្រែប្រួល ដោយសង្គមខ្មែរសំដៅលើគារវត្ថុដែលសាងដោយឥដ្ឋ ស៊ីម៉ង់ ។ល។ សម្រាប់តម្កល់រក្សាអដ្ឋិធាតុ។

ដូចនេះ សម្រាប់សង្គមខ្មែរបច្ចុប្បន្ន បញ្ញត្តិព្រះភូមិឬរានទេវតា គឺសំដៅលើគារវត្ថុសម្រាប់សែនព្រេនសុំឱ្យម្ចាស់ទឹកម្ចាស់ដីនិងទេវតាជួយគ្រងរក្សាភូមិដ្ឋាន ផ្ទះសម្បែង និង គ្រួសារ ឱ្យបានសេចក្តីសុខសេចក្តីសប្បាយ។ ឯបញ្ញត្តិ ចេតិយ គឺសំដៅដល់គារវត្ថុសម្រាប់តម្កល់រក្សាអដ្ឋិធាតុ។

ប្រជាជននៅឃុំត្រពាំងធំខាងជើងនៅតែហៅថា ព្រះភូមិឬរានទេវតា ទោះបីជាខ្លឹមសាររបស់វាបានផ្លាស់ប្តូរពីគារវត្ថុសម្រាប់សែនព្រេនសុំការជួយថែរក្សាភូមិករនិងជួយឱ្យមានសេចក្តីសុខសេចក្តីសប្បាយដល់គ្រួសារ ទៅជាគោរវត្ថុសម្រាប់តម្កល់រក្សាអដ្ឋិធាតុទៅហើយក្តី។ ការហៅបែបនេះ គឺដោយសារទម្រង់ទ្រង់ទ្រាយនៃព្រះភូមិឬរានទេវតានោះនៅរក្សាលក្ខណៈដើមរបស់វាជាមូលដ្ឋាននៅឡើយ ដោយគ្រាន់តែមានការប្រែប្រួលផ្នែកទំហំនិងបន្ថែមទ្វារកញ្ចក់សម្រាប់បិទរក្សាសុវត្ថិភាពអដ្ឋិធាតុប៉ុណ្ណោះ។ បច្ចុប្បន្ន ប្រជាជនខ្លះបានសន្មត់បែងចែករវាងព្រះភូមិនិងរានទេវតា ដោយរានទេវតាមានទំហំធំ ស្អាតល្អ មានទ្វារកញ្ចក់ និង សម្រាប់តម្កល់រក្សាអដ្ឋិធាតុ ឯព្រះភូមិមានទំហំតូច អាចមានទ្វារឬមិនមានទ្វារកញ្ចក់ និង សម្រាប់សែនព្រេនសុំសេចក្តីសុខសេចក្តីសប្បាយដល់ផ្ទះសម្បែងនិងក្រុមគ្រួសារ ទោះបីជាវាមានទម្រង់ដូចគ្នាក៏ដោយ។ ឯប្រជាជនខ្លះទៀតហៅព្រះភូមិឬរានទេវតាដែលប្រើដាក់តម្កល់រក្សាអដ្ឋិធាតុនោះថា ប្រាសាទ។

ជាទូទៅ ប្រសិនបើប្រជាជនយកព្រះភូមិឬរានទេវតាសម្រាប់តម្កល់រក្សាអដ្ឋិធាតុ គេតែងរៀបដាក់តម្កល់វានៅលើខឿនដែលមានស្ថានភាពរឹងមាំនិងខ្ពស់ជាងសណ្ឋានដីធម្មតា។ ករណីខ្លះ គេដាក់ជើងវានៅក្នុងលូអណ្តូងទឹកមួយកង់ឬពាងដែលមានរក្សាទឹកក្នុងនោះ។ ធ្វើបែបនេះជាការបង្ហាញនូវសេចក្តីគោរពស្រឡាញ់ដល់អដ្ឋិធាតុនៃសពផងនិងជាជំនឿក្នុងការទទួលបានភាពត្រជាក់ត្រជុំ សេចក្តីសុខសេចក្តីសប្បាយ។



ការតម្កល់រក្សាអដ្ឋិធាតុក្នុងរានទេវតាឬព្រះភូមិ(មានទ្វារកញ្ចក់)
ដែលរៀបដាក់លើខឿន និង ដាក់ទឹក (ភូមិព្រៃតាឡី)



ការតម្កល់ក្បាអដ្ឋិធាតុក្នុងរានទេវតាឬព្រះភូមិ ដែលដាក់ក្នុងលូមានទឹក



ការតម្កល់ក្បាអដ្ឋិធាតុក្នុងរានទេវតាឬព្រះភូមិ ដែលមានចាក់សាបនិងរៀបផ្កាព័ទ្ធជុំវិញជើងក្រោម

ទន្ទឹមនេះ គេបានបង្កើតនូវចេតិយមានទំហំតូចល្មម (ប៉ុនឬធំជាងព្រះភូមិឬរានទេវតាបន្តិច) សម្រាប់តម្កល់ក្បាអដ្ឋិធាតុ ហើយដែលប្រជាជនហៅថា *ចេតិយ* ព្រោះទម្រង់ទ្រង់ទ្រាយរបស់វាមានសណ្ឋានជាចេតិយ។ ដូច្នេះ ប្រជាជនបានហៅឈ្មោះគាវវត្ថុទាំងនេះដោយផ្អែកជាមូលដ្ឋានលើទម្រង់របស់វា តែមិនមែនអាស្រ័យលើខ្លឹមសាររបស់វាឡើយ។

ក្នុងន័យទស្សនវិជ្ជាបដិសំយោគ រវាងខ្លឹមសារនិងទម្រង់ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នា គឺ ខ្លឹមសារកំណត់ទម្រង់ ឯទម្រង់ចំណុះខ្លឹមសារ។ [12] តាមន័យនេះ ទោះបីជាព្រះភូមិឬរានទេវតានៅរក្សាទម្រង់ជាមូលដ្ឋានរបស់វាក្តី តែប្រសិនបើខ្លឹមសាររបស់វាបានផ្លាស់ប្តូរទៅជាគាវវត្ថុសម្រាប់តម្កល់ក្បាអដ្ឋិធាតុហើយ នោះគេត្រូវហៅថា *ចេតិយ* ។

[12] ឆយ យីហ៊ាង ៖ *វិធីបដិសំយោគ* សុខលាភបោះពុម្ព ភ្នំពេញ ២០០៧ ទំព័រ ៥២ ។

ចលនាតម្កល់រក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតានាពេលអនាគត

នៅចំណុចនេះ ដើម្បីយើងអាចដឹងអំពីស្ថានភាពនៃការប្រតិបត្តិការតម្កល់រក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតានាពេលអនាគត យើងអាចពិចារណាលើកត្តាបួនជាសំខាន់។ កត្តាទាំងបួននោះគឺ កត្តាសុវត្ថិភាពអដ្ឋិធាតុ កត្តាសេដ្ឋកិច្ច ភាពងាយស្រួលក្នុងការគោរពប្រណិប័តន៍ និង ទំនោរនៃរបៀបទុកដាក់សពរបស់ប្រជាជន។

យើងបានលើកឡើងខាងលើរួចហើយអំពី កត្តាសុវត្ថិភាពនៃអដ្ឋិធាតុ កត្តាសេដ្ឋកិច្ច និង ភាពងាយស្រួលក្នុងការគោរពប្រណិប័តន៍អដ្ឋិធាតុនៃសព នៅពេលប្រជាជនប្រតិបត្តិការតម្កល់រក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតានៅក្បែរផ្ទះ។ ការចំណាយថវិកាតិច មានសុវត្ថិភាព ហើយងាយស្រួលក្នុងការគោរពប្រណិប័តន៍អដ្ឋិធាតុនៃសពមនុស្សជាទីគោរពស្រឡាញ់របស់ខ្លួន នឹងធ្វើឱ្យប្រជាជននៅតែបន្តប្រតិបត្តិចលនានេះបន្តទៀត ជាពិសេសប្រជាជនដែលមានជីវភាពកម្រិតមធ្យមនិងជីវភាពកម្រិតទាប។ ជាងនេះទៀត ការតម្កល់រក្សាអដ្ឋិធាតុនៅក្បែរផ្ទះ ក្បែរខ្លួន ក៏ធ្វើឱ្យសមាជិកគ្រួសារមានភាពកក់ក្ដៅខាងផ្លូវចិត្ត ផ្លូវស្មារតីផងដែរ។

ទាក់ទងនឹងទំនោរនៃរបៀបទុកដាក់សព បច្ចុប្បន្ន ប្រជាជននៅឃុំត្រពាំងធំខាងជើងនិយមទុកដាក់សពដោយការបូជា ដោយសារការបូជាសពនាពេលបច្ចុប្បន្នមានលក្ខណៈងាយស្រួល ព្រោះមានភ្នាក់ងារទទួលបម្រើសេវាកម្មខាងការបូជាសពដោយប្រើមេរុចល័ត។ តាមរយៈការបូជាសពប្រើមេរុចល័តនេះ អដ្ឋិធាតុនៃសពនឹងស្ថិតនៅក្នុងទីវត្ថុកំណត់មួយ ដោយមិនស្ថិតនៅផ្ទាល់នឹងដីដូចមុនទៀតឡើយ។ ធាតុដែលរើសមករក្សាទុកក្នុងកោដ្ឋនឹងត្រូវមានទីសមគួរសម្រាប់តម្កល់រក្សាវា ហើយប្រជាជននឹងប្រតិបត្តិការតម្កល់រក្សានៅក្នុងព្រះភូមិឬរានទេវតាបន្តទៀត ដោយផ្អែកលើមូលហេតុបីខាងលើ។ ទន្ទឹមនោះ ពំនូនផ្នូរដែលកើតចេញពីការបូជាសពនឹងពុំសូវមានទៀតឡើយ។

បច្ចុប្បន្ន ចលនាតម្កល់រក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតាកំពុងមានការនិយមយ៉ាងផុលផុសនៅឃុំត្រពាំងធំខាងជើង។ នៅភូមិពាក់បង្អោង មានប្រជាជនប្រមាណ៧០%[13] បានតម្កល់រក្សាអដ្ឋិធាតុក្នុងព្រះភូមិឬរានទេវតា។ ចលនានេះនឹងកាន់តែរីកផុសផុលបន្តទៅទៀតទៅភូមិដទៃ។

## សេចក្ដីសន្និដ្ឋាន

តាមរយៈបំណកស្រាយខាងលើ យើងអាចសន្និដ្ឋានថា ប្រជាជននៅឃុំត្រពាំងធំខាងជើងដែលនិយមតម្កល់រក្សាអដ្ឋិធាតុនៅក្នុងព្រះភូមិឬរានទេវតា ក្នុងរយៈពេលប្រមាណជាជិតមួយទសវត្សរ៍ចុងក្រោយនេះ គឺដោយសារមូលហេតុបីសំខាន់៖ សុវត្ថិភាពនៃអដ្ឋិធាតុ សេដ្ឋកិច្ច និង ភាពងាយស្រួលក្នុងការគោរពប្រណិប័តន៍អដ្ឋិធាតុនៃសពមនុស្សជាទីគោរពស្រឡាញ់របស់ខ្លួន។ ចលនានេះនឹងកាន់តែរីកផុសផុលនៅក្នុងឃុំត្រពាំងធំខាងជើង និងនៅទីកន្លែងដទៃទៀតក្នុងប្រទេស ដោយបច្ចុប្បន្នចលនានេះក៏កំពុងមានការប្រតិបត្តិនៅទីកន្លែងដទៃដូចគ្នារួចហើយ។ ផ្អែកតាមទស្សនវិជ្ជាបដិសំយោគ

[13] ហេង សុផាត អាយុ៥៦ឆ្នាំ រស់នៅក្នុងភូមិពាក់បង្អោង ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសន៍ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦)។

ដែលថា ខ្លឹមសារកំណត់ទម្រង់ ព្រះភូមិឬរានទេវតាដែលបានផ្លាស់ប្តូរខ្លឹមសារប្រើជាគារវត្ថុតម្កល់រក្សាអដ្ឋិធាតុ គួរហៅថា ចេតិយ ។

ទំនោរនិយមតម្កល់រក្សាអដ្ឋិធាតុនៅក្បែរផ្ទះ ក្បែរខ្លួន ក៏បានបង្ហាញផងដែរនូវការប្រែប្រួលឥរិយាបថរបស់ប្រជាជនចំពោះវត្តអារាម ដែលជាទីគោពសក្ការៈ និង ការប្រែប្រួលឥរិយាបថរបស់គ្រួសារចំពោះអដ្ឋិធាតុនៃសពមនុស្សជាទីគោរពស្រឡាញ់របស់ខ្លួន។ ពីមុន គ្រួសារសពភាគច្រើនមានភាពស្ទាក់ស្ទើរក្នុងការយកអដ្ឋិធាតុនៃសពសមាជិកគ្រួសាររបស់ខ្លួនមកតម្កល់រក្សាក្នុងផ្ទះ ឬ ក្បែរផ្ទះឡើយ ដោយគេយល់ថា អដ្ឋិធាតុជារបស់គួរឱ្យខ្លាចរអា ឬ ជារបស់នាំមកនូវអកុសល្យផ្សេងៗ។ ប៉ុន្តែបច្ចុប្បន្ន គ្រួសារហ៊ានយកអដ្ឋិធាតុមកតម្កល់រក្សាក្បែរខ្លួន លែងខ្លាចរអាច ហើយយល់ថា អំណាចនៃអដ្ឋិធាតុនោះនឹងឃុំគ្រងរក្សាគ្រួសារឱ្យមានសេចក្តីសុខសប្បាយ។

## ឯកសារពិគ្រោះ


### ស្នាដៃនិពន្ធ

- ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ ៖ *ប្រជុំរឿងព្រេងខ្មែរ* បោះពុម្ពលើកទី២ ២០០៣ ។
- ខ្លូត ធីតា ៖ *ទស្សនវិជ្ជាប្រវត្តិសាស្ត្រខ្មែរសម័យបុរេប្រវត្តិ នគរភ្នំ និងចេនឡា* ២០១៣។
- ឆយ យីហ៊ាង ៖ *វិធីបដិសំឃោគ* សុខលាភបោះពុម្ព ភ្នំពេញ ២០០៧ ។
- ត្រឹង ងា ៖ *អរិយធម៌ខ្មែរ* ថ្នាក់បញ្ចប់ បោះពុម្ពលើកទី៣ ១៩៧៤។
- ប្រែង ពិសិដ្ឋ ៖ *ផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យលើវប្បធម៌ខ្មែរ* ២០១១។
- លី ជាមតេង ៖ *កំណត់ហេតុរបស់ជីវិតាក្វាន់អំពីប្រពៃណីអ្នកស្រុកចេនឡា* បោះពុម្ពលើកទី៣ ភ្នំពេញ ១៩៧៣។

### កិច្ចសម្ភាស

- ជិន សារឿន អាយុ៧៦ឆ្នាំ អាចារ្យវត្តមង្គលមានលក្ខណ៍ រស់នៅក្នុងភូមិព្រៃដក់ពរ (សម្ភាសន៍ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦)។
- ដួង ជឿន អាយុ៧៨ឆ្នាំ អាចារ្យវត្តអង្គស្អាត រស់នៅភូមិព្រៃស្បាត (សម្ភាសន៍ថ្ងៃ២៧ ខែតុលា ឆ្នាំ២០១៦)។
- ណុប សារិន អាយុ៣៩ឆ្នាំ ប្រធានភូមិព្រៃដក់ពរ ( សម្ភាសន៍ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៦)។
- សៀក ឈួន (ហៅអាចារ្យណុប) អាយុ៧៩ អាចារ្យវត្តសិរីជំណាក់ (សម្ភាសន៍ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦)។
- ហេង សុផាត អាយុ៥៦ឆ្នាំ រស់នៅភូមិពាក់បង្អោង (សម្ភាសន៍ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦)។
- ហ៊ីង នឿន អាយុ៧០ឆ្នាំ ប្រធានភូមិពាក់បង្អោង (សម្ភាសន៍ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៦)។
- អ៊ិត ស៊ីន អាយុ៥៦ឆ្នាំ អ្នកលក់រានទេវតារស់នៅក្នុងភូមិព្រៃស្បាត (សម្ភាសន៍ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦)។